មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## ម.ស.ម.ក រៀបចំសិក្ខាសាលាស្តីពី យុវជន និងកំណែទម្រង់ការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤

នៅថ្ងៃទី២០ និង២១ ខែមិថុនា ឆ្នាំ២០១៤ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") នឹងរៀបចំសិក្ខាសាលាស្តីពី "យុវជន និងកំណែទម្រង់ការបោះឆ្នោត" ក្នុងគោលបំណងផ្តល់ឱកាសឲ្យយុវជនចូលរួមកំណត់ពីបញ្ហាព្រួយបារម្ភសំខាន់ៗដែលទាក់ទងកំណែទម្រង់ការបោះឆ្នោត និងបង្កើតអនុសាសន៍ ព្រមទាំងរៀនអំពីបញ្ហាសំខាន់ៗទាក់ទងការចូលរួមក្នុងវិស័យនយោបាយ និងកំណែទម្រង់ការបោះឆ្នោត។ សិក្ខាសាលានេះនឹងផ្តល់ឱកាសឲ្យយុវជនបង្កើនសមត្ថភាពរបស់ខ្លួននៅក្នុងការធ្វើសកម្មភាពយុទ្ធនាការ និងតស៊ូមតិ ឬកំណែទម្រង់ការបោះឆ្នោត និងបង្កើតឱកាសឲ្យយុវជនចងជាបណ្តាញក្នុងចំណោមយុវជនដែលចូលរួមក្នុងសិក្ខាសាលានេះ។ ក្នុងសិក្ខាសាលានេះនឹងមានយុវជនចូលរួមប្រមាណ ៥០ នាក់។

សិក្ខាសាលានេះរៀបចំឡើងគឺជាផ្នែកនៃគម្រោងកៀរគរយុវជនជុំវិញកំណែទម្រង់ការបោះឆ្នោតរបស់ ម.ស.ម.ក. ដែលមានគោលបំណងលើកកម្ពស់ការយល់ដឹង និងជម្រុញឲ្យមានការចូលរួមពីប្រជាជន ជាពិសេស យុវជនដែលកាន់តែមានសំឡេងច្រើនក្នុងការទាមទារឲ្យមានការផ្លាស់ប្តូរ នៅក្នុងការជជែកពិភាក្សាអំពីកំណែទម្រង់ការបោះឆ្នោត ដើម្បីចូលរួមចំណែកបង្កើតអនុសាសន៍សំខាន់ៗដែលឆ្លុះបញ្ចាំងពីគ្រប់ស្ថាប័ន។

បន្ទាប់ពីសិក្ខាសាលានេះ បញ្ហាដែលត្រូវលើកឡើង និងអនុសាសន៍របស់អ្នកចូលរួមនឹងប្រមូលដាក់បញ្ចូលគ្នាដើម្បីតាក់តែងជារបាយការណ៍សង្ខេបខ្លី ហើយបញ្ជូនរបាយការណ៍នេះទៅកាន់ស្ថាប័នពាក់ព័ន្ធ ដូចជាគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាដើម ដើម្បីទទួលបានយោបល់ត្រលប់ និងជំរុញឲ្យមានកិច្ចសន្ទនាផងដែរ។

### <u>កាលបរិច្ឆេទ និងទីកន្លែង</u>

កាលបរិច្ឆេទ ៖ **ថ្ងៃទី២០ និង២១ ខែមិថុនា ឆ្នាំ២០១៤**

ពេលវេលា ៖ **ម៉ោង ០៨.០០ ព្រឹក ដល់ ៥.០០ល្ងាច**

ទីកន្លែង ៖ **ភោជនីយដ្ឋានខ្មែរសូរិន ផ្ទះលេខ១១A ផ្លូវលេខ៥៧ បឹងកេងកង១ ចំការមន រាជធានីភ្នំពេញ។**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោកស្រី ជរ ច័ន្ទធីតា អ្នកស្រាវជ្រាវជាន់ខ្ពស់ តាមរយៈទូរសព្ទលេខ +៨៥៥ (0)១២ ៥១៥ ៥០៦ ឬអ៊ីម៉ែល** thyda@cchrcambodia.org

**បណ្ណាធិការ ៖**

ម.ស.ម.ក ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងនឹងការធ្វើទារុណកម្មពិភពលោក (OMCT) ជាបណ្តាញជួយសង្គ្រោះចំពោះអំពើទារុណកម្ម។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងជាជ័យលាភីទទួលបានពានរង្វាន់ផ្នែកទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៃសាកលវិទ្យាល័យឃ្វីនហ្សឡែន ក្នុងរដ្ឋប្រីសបែន ប្រទេសអូស្ត្រាលី។